# រាជរដ្ឋាភិបាលកម្ពុជា
# THE ROYAL GOVERNMENT OF CAMBODIA

## ក្រសួងមុខងារសាធារណៈ
MINISTRY OF CIVIL SERVICE

# គោលនយោបាយ
# POLICY
# ស្តីពី
# ON
# ការផ្តល់សេវាសាធារណៈ
# PUBLIC SERVICE DELIVERY

## "បំរើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង"
## "Serving People Better"

អនុម័តដោយគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ

ADOPTED BY THE FULL MEETING OF THE COUNCIL OF MINISTERS

ថ្ងៃទី ០៥ ឧសភា ២០០៦

5 MAY 2006

# គោលនយោបាយ

## ស្តីពី

# ការផ្តល់សេវាសាធារណៈ

“បំរើប្រជាពលរដ្ឋ

ឱ្យបានកាន់តែល្អប្រសើរឡើង”



# លក្ខណៈសម្បត្តិ នៃរដ្ឋបាលសាធារណៈ

ប្រទេសកម្ពុជាក្នុងរយៈពេលជាងមួយទសវត្សកន្លងទៅនេះ បានប្រែក្លាយខ្លួនយ៉ាងឆាប់រហ័សពីប្រទេស ដែលធ្លាប់តែញ៉ាំញីដោយសារសង្គ្រាមស៊ីវិលរាប់ទសវត្សទៅជាប្រទេសជាតិដែលមានសន្តិភាព ស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម ប្រជាធិបតេយ្យ ការគោរពសិទ្ធិសេរីភាព កំណើនសេដ្ឋកិច្ចខ្ពស់ និងភាពក្រីក្រត្រូវបានកាត់បន្ថយជាបន្តបន្ទាប់។

តាងនាមរាជរដ្ឋាភិបាល ខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះការខិតខំប្រឹងប្រែង ព្យាយាមអនុវត្តគោលនយោបាយ និងកម្មវិធីនានា របស់រាជរដ្ឋាភិបាល ដែលសម្រេចបានសមិទ្ធផលជាច្រើនគួរជាទីមោទនៈ។ សមិទ្ធផលដ៏ច្រើនទាំងនេះ មិនត្រូវធ្វើ

ឱ្យយើងភ្លេចនូវគោលដៅជាយុទ្ធសាស្ត្រ និងមើលរំលងចំពោះបញ្ហាប្រឈមនានាដែលកំពុងជួបប្រទះ។

យុទ្ធសាស្ត្រ និងកម្មវិធីដែលបានអនុម័តនាពេលថ្មីៗកន្លងទៅនេះ ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការសកម្មភាពអភិបាលកិច្ចទី ២ បានបង្ហាញនូវទិសដៅយ៉ាងច្បាស់លាស់ដើម្បីជាត្រីវិស័យក្នុងការអនុវត្តការដ្ឋានកំណែទម្រង់ជាអាទិភាពនានារបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ។

កម្ពុជា គ្មានជម្រើសណាល្អប្រសើរក្រៅតែពីការធ្វើកំណែទម្រង់ទេ នៅក្នុងឱកាសដែលប្រទេសជាតិយើងកំពុងតែទទួលផលចំណេញពីសន្តិភាព និងស្ថិរភាពដែលយើងខិតខំកសាងនិងការពារបាន។ រដ្ឋបាលសាធារណៈសព្វថ្ងៃ ត្រូវធ្វើកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅថែមទៀត ដើម្បីប្រែក្លាយខ្លួនឱ្យទៅជា **អ្នកផ្តល់សេវា**

ដ៏មានប្រសិទ្ធភាព និងជា **ដៃគូអភិវឌ្ឍន៍** ដែលអាចទុកចិត្តបាន សំដៅ "**បំរើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង**"។ ក្នុងឱកាសដ៏ល្អនេះ គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលសាធារណៈ ត្រូវតែបានពង្រឹងដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរប្រកបដោយនិរន្តរភាព និងពង្រឹងភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់របស់កម្ពុជា។

ក្នុងន័យនេះ ខ្ញុំយល់ឃើញថារដ្ឋបាលសាធារណៈត្រូវមានលក្ខណៈសម្បត្តិសំខាន់៧បួន ដូចខាងក្រោម ៖

**ទឹកចិត្តបំរើការងារមោះមុត** ៖ រដ្ឋបាលសាធារណៈដែលមោះមុតក្នុងការងារ និងមានការលើកកំពស់ទឹកចិត្តការងាររបស់មន្ត្រីរាជការ ។

***ភក្តីភាព*** ៖ រដ្ឋបាលសាធារណៈដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាល និងស្ថាប័នរដ្ឋ ត្រូវមានភក្តីភាពចំពោះរដ្ឋ និងប្រជាពលរដ្ឋ។

**ផ្តោតលើសេវា** : រដ្ឋបាលសាធារណៈត្រូវប្រែក្លាយខ្លួនពី "**អ្នកគ្រប់គ្រង**" ទៅជា "**អ្នកផ្តល់សេវា**" គួរជាទីគោរព និងមានភាពត្រឹមត្រូវក្នុងការបំរើ និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។

**សីលធម៌វិជ្ជាជីវៈ** : រដ្ឋបាលសាធារណៈ ត្រូវបំពេញភារកិច្ចរបស់ខ្លួន ប្រកបដោយតម្លាភាព សមត្ថភាព និងប្រសិទ្ធភាព។

លក្ខណៈសម្បត្តិរបស់រដ្ឋបាលខាងលើនេះ អាចសម្រេចទៅបានទាល់តែអកប្បកិរិយា និងទម្លាប់ការងាររបស់មន្ត្រីរាជការត្រូវបានផ្លាស់ប្តូរ។

ដើម្បីសម្រេចគោលដៅខាងលើ រាជរដ្ឋាភិបាលបានអនុម័តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលជាស្នូលមួយនៃយុទ្ធសាស្ត្រចតុកោណ ហើយដែលកំពុងដាក់ឱ្យអនុវត្តយ៉ាងសកម្ម។ ជោគជ័យនៃការងារកំណែ

ទម្រង់នេះ គឺអាស្រ័យទៅលើល្បឿននៃការផ្លាស់ប្តូរផ្នត់គំនិត និងទម្លាប់ការងាររបស់មន្ត្រីរាជការពីអ្នកគ្រប់គ្រង ទៅជាអ្នកផ្តល់សេវា។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា មន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័ន និងគ្រប់លំដាប់ថ្នាក់ នឹងពង្រឹងកិច្ចសហការឱ្យកាន់តែជិតស្និទ្ធថែមទៀតក្នុងការអនុវត្តគោលនយោបាយនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ជាពិសេសត្រូវយកចិត្តទុកដាក់ទៅលើ :

- ភាពងាយស្រួលក្នុងការយកសេវាទៅប្រើប្រាស់
- ភាពគួរសម រួសរាយរាក់ទាក់ និងការយកចិត្តទុកដាក់ចំពោះអ្នកប្រើប្រាស់សេវា
- ការផ្តល់ចម្លើយងាយយល់នៅក្នុងថេរវេលា ដែលបានកំណត់ជាមុន និង
- ការផ្តល់ការបំភ្លឺរាល់ការទាមទាររបស់អ្នកប្រើប្រាស់សេវា ។

ក្នុងទិសដៅ **បំរើប្រជាពលរដ្ឋ ឱ្យបានកាន់តែល្អប្រសើរឡើង ។**

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០០៦

**ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា**
**និងជាប្រធានឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**



# អារម្ភកថា

នៅក្នុងនីតិកាលទី២ នៃរដ្ឋសភា រាជរដ្ឋាភិបាល បានសម្រេចនូវសមិទ្ធផលដ៏សំខាន់មួយ គឺការកសាងមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងមុខងារសាធារណៈ ដែលរួមមាន : ការធ្វើជំរឿនមន្ត្រីរាជការស៊ីវិលទូទាំងប្រទេស ការរៀបចំលក្ខន្តិកៈដោយឡែកតាមប្រភេទក្របខ័ណ្ឌនីមួយៗ ការបង្កើត និង ដាក់ឱ្យដំណើរការនូវប្រព័ន្ធចំណាត់ថ្នាក់តាមប្រភេទក្របខ័ណ្ឌ **ក ខ គ ឃ** និងប្រព័ន្ធបៀវត្សរ៍ថ្មី ការដាក់ឱ្យដំណើរការនូវតារាងទូទាត់បៀវត្សរ៍តាមព័ត៌មានវិទ្យា ការធ្វើសមាហរណកម្មមន្ត្រីរាជការទៅក្នុងប្រព័ន្ធចំណាត់ថ្នាក់ថ្មី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍តាមព័ត៌មានវិទ្យា ការបង្កើតប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗទៀត

ដែលធ្វើឱ្យប្រៀវត្សរ៍មធ្យមរបស់មន្ត្រីរាជការបានកើន ឡើងប្រមាណ ១៣៨% ក្នុងចន្លោះឆ្នាំ២០០២-២០០៦ និងការបង្កើតលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ។

ផ្អែកលើមូលដ្ឋានគ្រឹះនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវកម្មវិធីកំណែទម្រង់រដ្ឋបាល ៥ ឆ្នាំទៅមុខ (២០០៤-២០០៨) ដោយបានកំណត់យ៉ាងច្បាស់លាស់អំពីគោលដៅចម្បង គឺ " **បំរើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង**" ។ យុទ្ធសាស្ត្រនៃកម្មវិធីនេះ ផ្អែកលើគោលគ្រឹះសំខាន់៤ គឺ: ១-ការកែលំអសេវាសាធារណៈ ២-ការបង្កើនប្រៀវត្សរ៍ និងការពង្រឹងការគ្រប់គ្រងនិយោជន៍ ៣-ការអភិវឌ្ឍសមត្ថភាព និង៤-ការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមាន

កម្មវិធីកន្ទ្បោមអាទិភាពជាស្នូលនៃយុទ្ធសាស្ត្រ ។

បន្ថែមពីលើឯកសារស្តីពីផែនការសកម្មភាព អភិបាលកិច្ច ទី ២ ដែលគណៈរដ្ឋមន្ត្រីបានអនុម័ត កាល ពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៦ ក្រុមប្រឹក្សាកំណែទម្រង់ រដ្ឋបាល បាននិងកំពុងរៀបចំឯកសារគោលនយោបាយ នានាជាច្រើន សំដៅពង្រីកវិសាលភាព និងធ្វើឱ្យកាន់ តែស៊ីជម្រៅថែមទៀតនូវការដ្ឋានកំណែទម្រង់នានាដើម្បី សម្រេចឱ្យបានជោគជ័យ នូវយុទ្ធសាស្ត្រចតុកោណ មានជាអាទិ៍ : គោលនយោបាយស្តីពីការផ្តល់សេវា សាធារណៈ គោលការណ៍រួមនៃការផ្តល់សេវាសា-ធារណៈតាមយន្តការការិយាល័យច្រកចេញចូលតែមួយ គោលនយោបាយស្តីពីការគ្រប់គ្រងធនធានមនុស្ស គោលនយោបាយស្តីពីការអភិវឌ្ឍធនធានមនុស្ស គោលនយោបាយស្តីពីលាភការ គោលនយោបាយស្តីពី

ការគ្រប់គ្រងនិយោជន៍ ក្របខ័ណ្ឌគ្រប់គ្រងសម្រាប់ការអភិវឌ្ឍសមត្ថភាព និងការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាជំនួយដល់ការផ្តល់សេវាសាធារណៈ និងការងារគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួងស្ថាប័ននីមួយៗ ។

គោលនយោបាយស្តីពី **ការផ្តល់សេវាសាធារណៈ** ដូចមាននៅក្នុងកូនសៀវភៅនេះ គឺជាលទ្ធផលនៃការចូលរួមពិភាក្សា និងផ្លាស់ប្តូរយោបល់ជាច្រើនលើកច្រើនសាពីគ្រប់ក្រសួង ស្ថាប័នតាមរយៈកិច្ចប្រជុំអន្តរក្រសួង រហូតដល់ទទួលបានការអនុម័តពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៦ កន្លងទៅនេះ ។

ខ្ញុំសូមឆ្លៀតឱកាសនេះថ្លែងអំណរគុណចំពោះ

តំណាងគ្រប់ក្រសួង ស្ថាប័នទាំងអស់ ដែលបានចូលរួមផ្តល់នូវអនុសាសន៍ល្អៗជាច្រើន ដែលធ្វើឱ្យឯកសារគោលនយោបាយនេះ មានខ្លឹមសារពេញលេញ និងគ្រប់ជ្រុងជ្រោយ ។

ឯកសារគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ បង្ហាញឱ្យឃើញអំពី និយមន័យ ប្រភេទនៃសេវាសាធារណៈរបស់រដ្ឋ គោលដៅ វិធីសាស្ត្រ យន្តការនៃការអនុវត្ត ការកែលំអបទដ្ឋានគតិយុត្ត និងការសម្របសម្រួលអនុវត្ត ។

កូនសៀវភៅនេះត្រូវបានរៀបចំឡើងមិនត្រឹមតែសម្រាប់ការសិក្សាស្វែងយល់របស់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់រូបប៉ុណ្ណោះទេ ប៉ុន្តែនឹងបង្ហាញផងដែរអំពីវិសាលភាពនៃសកម្មភាពជាអាទិភាពរបស់

រាជរដ្ឋាភិបាលលើការដ្ឋានកំណែទម្រង់រដ្ឋបាល សំដៅធ្វើឱ្យរដ្ឋបាលសាធារណៈ មានសមត្ថភាពបម្រើប្រជាពលរដ្ឋឱ្យកាន់តែបានល្អប្រសើរឡើងជាលំដាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ មិថុនា ឆ្នាំ ២០០៦

**សុខ អាន**

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

អនុប្រធានអចិន្ត្រៃយ៍ ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

និងជាប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល



សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
ដឹកនាំសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី



ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន កំពុងធ្វើការអធិប្បាយ
ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ០៥-០៥-២០០៦

## មាតិកា


**លក្ខណៈសម្បត្តិនៃរដ្ឋបាលសាធារណៈ**............i

**អារម្ភកថា**.......................................................vii

**សេចក្តីផ្តើម**....................................................... ១

I- **និយមន័យ** ..................................................... ៦

II-**ប្រភេទនៃសេវាសាធារណៈរបស់រដ្ឋ** .......... ៨

១- ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ .......... ៨

២- ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម.................៩

៣- ចង្កោមសេវាពាក់ព័ន្ធយុត្តិធម៌ និងអាជ្ញាកណ្តាល..១០

៤- ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូច និង មធ្យម បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ........... ១២

៥- ចង្កោមសេវាសង្គមកិច្ច វប្បធម៌និងកិច្ចការនារី ....១៦



មាតិកា

លក្ខណៈសម្បត្តិនៃរដ្ឋបាលសាធារណៈ........... i

អារម្ភកថា.......................................................vii

សេចក្តីផ្តើម....................................................... ១

I- និយមន័យ....................................................... ៦

II-ប្រភេទនៃសេវាសាធារណៈរបស់រដ្ឋ ............ ៨

១- ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ .......... ៨

២- ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ................. ៩

៣- ចង្កោមសេវាពាក់ព័ន្ធយុត្តិធម៌ និងអាជ្ញាកណ្តាល. ១០

៤- ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូច និង មធ្យម បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ........... ១២

៥- ចង្កោមសេវាសង្គមកិច្ច វប្បធម៌និងកិច្ចការនារី.... ១៦



មាតិកា

លក្ខណៈសម្បត្តិនៃរដ្ឋបាលសាធារណៈ............i

អារម្ភកថា.......................................................vii

សេចក្តីផ្តើម....................................................... ១

I- និយមន័យ ..................................................... ៦

II-ប្រភេទនៃសេវាសាធារណៈរបស់រដ្ឋ .......... ៨

១- ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ .......... ៨

២- ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម.................៩

៣- ចង្កោមសេវាពាក់ព័ន្ធយុត្តិធម៌ និងអាជ្ញាកណ្តាល..១០

៤- ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូច និង មធ្យម បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ........... ១២

៥- ចង្កោមសេវាសង្គមកិច្ច វប្បធម៌និងកិច្ចការនារី ....១៦



មាតិកា

លក្ខណៈសម្បត្តិនៃរដ្ឋបាលសាធារណៈ........... i

អារម្ភកថា.......................................................vii

សេចក្តីផ្តើម....................................................... ១

I- និយមន័យ....................................................... ៦

II-ប្រភេទនៃសេវាសាធារណៈរបស់រដ្ឋ ............ ៨

១- ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ .......... ៨

២- ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ................. ៩

៣- ចង្កោមសេវាពាក់ព័ន្ធយុត្តិធម៌ និងអាជ្ញាកណ្តាល. ១០

៤- ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូច និង មធ្យម បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ........... ១២

៥- ចង្កោមសេវាសង្គមកិច្ច វប្បធម៌និងកិច្ចការនារី.... ១៦

៦- ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនា
សម្ព័ន្ធរូបវ័ន្ត ........ ១៧
៧- ចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូល ការធ្វើ
វិចារណកម្មចំណាយ និងការបើកផ្តល់ ........ ១៨
III-**គោលដៅ** ........ ២១
IV-**វិធីសាស្ត្រ** ........ ២៥
១- ផ្នែកជួរមុខ ........ ២៧
២- ផ្នែកទ្រទ្រង់ ........ ២៨
ក- ធនធានមនុស្ស ........ ២៩
ខ- ធនធានហិរញ្ញវត្ថុ ........ ៣០
គ- ការធ្វើផែនការ ........ ៣០
ឃ-ការធ្វើអធិការកិច្ច និង ការវាយតម្លៃ ........ ៣០
ង- បច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ ........ ៣១
V-**យន្តការនៃការអនុវត្ត** ........ ៣៣
១- ការកែលំអ កិច្ចដំណើរការការងារនៃការផ្តល់សេវា



៦- ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនា
សម្ព័ន្ធរូបវ័ន្ត ........ ១៧
៧- ចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូល ការធ្វើ
វិចារណកម្មចំណាយ និងការបើកផ្តល់ ........ ១៨
III-**គោលដៅ** ........ ២១
IV-**វិធីសាស្ត្រ** ........ ២៥
១- ផ្នែកជួរមុខ ........ ២៧
២- ផ្នែកទ្រទ្រង់ ........ ២៨
ក- ធនធានមនុស្ស ........ ២៩
ខ- ធនធានហិរញ្ញវត្ថុ ........ ៣០
គ- ការធ្វើផែនការ ........ ៣០
ឃ-ការធ្វើអធិការកិច្ច និង ការវាយតម្លៃ ........ ៣០
ង- បច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ ........ ៣១
V-**យន្តការនៃការអនុវត្ត** ........ ៣៣
១- ការកែលំអ កិច្ចដំណើរការការងារនៃការផ្តល់សេវា



៦- ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនា
សម្ព័ន្ធរូបវ័ន្ត ........ ១៧
៧- ចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូល ការធ្វើ
វិចារណកម្មចំណាយ និងការបើកផ្តល់ ........ ១៨
III-**គោលដៅ** ........ ២១
IV-**វិធីសាស្ត្រ** ........ ២៥
១- ផ្នែកជួរមុខ ........ ២៧
២- ផ្នែកទ្រទ្រង់ ........ ២៨
ក- ធនធានមនុស្ស ........ ២៩
ខ- ធនធានហិរញ្ញវត្ថុ ........ ៣០
គ- ការធ្វើផែនការ ........ ៣០
ឃ-ការធ្វើអធិការកិច្ច និង ការវាយតម្លៃ ........ ៣០
ង- បច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ ........ ៣១
V-**យន្តការនៃការអនុវត្ត** ........ ៣៣
១- ការកែលំអ កិច្ចដំណើរការការងារនៃការផ្តល់សេវា



៦- ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនា
សម្ព័ន្ធរូបវ័ន្ត ........ ១៧
៧- ចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូល ការធ្វើ
វិចារណកម្មចំណាយ និងការបើកផ្តល់ ........ ១៨
III-**គោលដៅ** ........ ២១
IV-**វិធីសាស្ត្រ** ........ ២៥
១- ផ្នែកជួរមុខ ........ ២៧
២- ផ្នែកទ្រទ្រង់ ........ ២៨
ក- ធនធានមនុស្ស ........ ២៩
ខ- ធនធានហិរញ្ញវត្ថុ ........ ៣០
គ- ការធ្វើផែនការ ........ ៣០
ឃ-ការធ្វើអធិការកិច្ច និង ការវាយតម្លៃ ........ ៣០
ង- បច្ចេកវិទ្យាព័ត៌មាន និង ទូរគមនាគមន៍ ........ ៣១
V-**យន្តការនៃការអនុវត្ត** ........ ៣៣
១- ការកែលំអ កិច្ចដំណើរការការងារនៃការផ្តល់សេវា

សាធារណៈ ........ ៣៤

២- ច្រកចេញចូលតែមួយ ........ ៣៤

៣- វិសហមជ្ឈការសេវាសាធារណៈ ........ ៣៦

៤- វិមជ្ឈការសេវាសាធារណៈ ........ ៣៧

៥- គ្រឹះស្ថានសាធារណៈរដ្ឋបាល ........ ៣៨

៦- សហគ្រាសសាធារណៈ ........ ៤០

ក- គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈ សេដ្ឋកិច្ច ........ ៤២

ខ- ក្រុមហ៊ុនរដ្ឋ ........ ៤៣

គ- ក្រុមហ៊ុនចម្រុះ ........ ៤៤

៧- កិច្ចសន្យា ........ ៤៦

៨- ភ្នាក់ងារប្រតិបត្តិការពិសេស ........ ៤៨

៩- ឯកជនភាវូបនីយកម្ម ........ ៥០

VI- **ការកែលំអបទដ្ឋានគតិយុត្ត** ........ ៥១

VII- **ការសម្របសម្រួលអនុវត្ត** ........ ៥៣



សាធារណៈ ........ ៣៤

២- ច្រកចេញចូលតែមួយ ........ ៣៤

៣- វិសហមជ្ឈការសេវាសាធារណៈ ........ ៣៦

៤- វិមជ្ឈការសេវាសាធារណៈ ........ ៣៧

៥- គ្រឹះស្ថានសាធារណៈរដ្ឋបាល ........ ៣៨

៦- សហគ្រាសសាធារណៈ ........ ៤០

ក- គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈ សេដ្ឋកិច្ច ........ ៤២

ខ- ក្រុមហ៊ុនរដ្ឋ ........ ៤៣

គ- ក្រុមហ៊ុនចម្រុះ ........ ៤៤

៧- កិច្ចសន្យា ........ ៤៦

៨- ភ្នាក់ងារប្រតិបត្តិការពិសេស ........ ៤៨

៩- ឯកជនភាវូបនីយកម្ម ........ ៥០

VI- **ការកែលំអបទដ្ឋានគតិយុត្ត** ........ ៥១

VII- **ការសម្របសម្រួលអនុវត្ត** ........ ៥៣



សាធារណៈ ........ ៣៤

២- ច្រកចេញចូលតែមួយ ........ ៣៤

៣- វិសហមជ្ឈការសេវាសាធារណៈ ........ ៣៦

៤- វិមជ្ឈការសេវាសាធារណៈ ........ ៣៧

៥- គ្រឹះស្ថានសាធារណៈរដ្ឋបាល ........ ៣៨

៦- សហគ្រាសសាធារណៈ ........ ៤០

ក- គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈ សេដ្ឋកិច្ច ........ ៤២

ខ- ក្រុមហ៊ុនរដ្ឋ ........ ៤៣

គ- ក្រុមហ៊ុនចម្រុះ ........ ៤៤

៧- កិច្ចសន្យា ........ ៤៦

៨- ភ្នាក់ងារប្រតិបត្តិការពិសេស ........ ៤៨

៩- ឯកជនភាវូបនីយកម្ម ........ ៥០

VI- **ការកែលំអបទដ្ឋានគតិយុត្ត** ........ ៥១

VII- **ការសម្របសម្រួលអនុវត្ត** ........ ៥៣



សាធារណៈ ........ ៣៤

២- ច្រកចេញចូលតែមួយ ........ ៣៤

៣- វិសហមជ្ឈការសេវាសាធារណៈ ........ ៣៦

៤- វិមជ្ឈការសេវាសាធារណៈ ........ ៣៧

៥- គ្រឹះស្ថានសាធារណៈរដ្ឋបាល ........ ៣៨

៦- សហគ្រាសសាធារណៈ ........ ៤០

ក- គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈ សេដ្ឋកិច្ច ........ ៤២

ខ- ក្រុមហ៊ុនរដ្ឋ ........ ៤៣

គ- ក្រុមហ៊ុនចម្រុះ ........ ៤៤

៧- កិច្ចសន្យា ........ ៤៦

៨- ភ្នាក់ងារប្រតិបត្តិការពិសេស ........ ៤៨

៩- ឯកជនភាវូបនីយកម្ម ........ ៥០

VI- **ការកែលំអបទដ្ឋានគតិយុត្ត** ........ ៥១

VII- **ការសម្របសម្រួលអនុវត្ត** ........ ៥៣

## សេចក្តីផ្តើម

បន្ទាប់ពីសម្រេចបានកិច្ចព្រមព្រៀងក្រុងប៉ារីស ថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១ និងដោយសារការអនុវត្តនយោបាយ ឈ្នះ-ឈ្នះ របស់រាជរដ្ឋាភិបាល ដែលដឹកនាំដោយសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** កម្ពុជាបានបញ្ចប់សង្គ្រាមស៊ីវិលដែលអូសបន្លាយជិតបីទសវត្សរ៍ មន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធនៃភាគីនយោបាយទាំងអស់ត្រូវបានធ្វើសមាហរណកម្មមកក្នុងសង្គមជាតិ ហើយ " រដ្ឋបាលសាធារណៈឯកភាពជាតិ " មួយបានកកើតឡើងនាដើមឆ្នាំ១៩៩៩។ ទាំងនេះ គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំមិនអាចកាត់ថ្លៃបាន និងជាបុរេលក្ខខណ្ឌ ដើម្បីធានាបាននូវសន្តិភាព សន្តិសុខ ស្ថិរភាព សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងការអភិវឌ្ឍប្រទេសជាតិ។

ផ្អែកលើសមិទ្ធផលដ៏ត្រចះត្រចង់ខាងលើនេះ

រាជរដ្ឋាភិបាល បានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការពង្រឹង នីតិរដ្ឋ និងអភិបាលកិច្ចល្អតាមរយៈការធ្វើកំណែទម្រង់ ជាជំហានៗ និងដោយមានការប្រុងប្រយ័ត្នលើវិស័យ អាទិភាពមួយចំនួន : កំណែទម្រង់រដ្ឋបាល ការប្រយុទ្ធ ប្រឆាំងអំពើពុករលួយ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិ ធម៌ ការរំសាយកងកំលាំងប្រដាប់អាវុធ កំណែទម្រង់កង កំលាំងប្រដាប់អាវុធ ការងារវិមជ្ឈការ និង វិសហមជ្ឈ ការ ការពង្រឹងការគ្រប់គ្រងចំណូល និងការធ្វើវិចារណ កម្មចំណាយ និងកំណែទម្រង់ការគ្រប់គ្រងធនធានធម្ម ជាតិ (ដីធ្លី ព្រៃឈើ និងជលផល)។ ព្រមពេលជាមួយ គ្នានោះដែរ រាជរដ្ឋាភិបាលបានរៀបចំគោលដៅ អភិវឌ្ឍន៍សហសវត្សកម្ពុជា ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចប្រាំឆ្នាំលើកទី២ (២០០១-២០០៥) និងយុទ្ធ សាស្រ្តជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥ ។ លើសពីនេះទៅទៀត កម្ពុជាក៏បានធ្វើសមាហរណកម្ម

ទៅក្នុងតំបន់ និងពិភពលោកផងដែរ ។

ការដ្ឋានដ៏សំខាន់ៗទាំងអស់នេះ កំពុងតែត្រូវបានបន្តដាក់ឱ្យអនុវត្តនៅក្នុងនីតិកាលទី ៣ នៃរដ្ឋសភា ហើយដែលតម្រូវឱ្យមានការកែទម្រង់ស៊ីជម្រៅមួយជំហានថែមទៀតក្នុងវិស័យអភិបាលកិច្ចល្អ ក្នុងនោះ កំណែទម្រង់រដ្ឋបាល គឺជាស្នូលអាទិភាពមួយ ដែលបានបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ ។

ទោះបីជារដ្ឋបាលសាធារណៈបានឆ្លងកាត់នូវការផ្លាស់ប្តូរ និងការធ្វើកំណែទម្រង់ជាបន្តបន្ទាប់យ៉ាងណាក៏ដោយ ក៏មិនទាន់ឆ្លើយតបបានទាំងស្រុងនៅឡើយទៅនឹងតម្រូវការរបស់ប្រទេសជាតិ ដែលកាន់តែមានទំហំធំឡើងៗ នៅក្នុងបរិបទនៃសកលភាវូបនីយកម្ម ។

ដើម្បីសម្រេចបានគោលដៅខាងលើនេះ រាជ

រដ្ឋាភិបាល បានដាក់ចេញនូវកម្មវិធីកំណែទម្រង់រដ្ឋបាល ២០០៤-២០០៨ ដែលមានមុំយុទ្ធសាស្ត្រសំខាន់ៗចំនួន ៤ រួមមាន : ១-ការកែលំអសេវាសាធារណៈ ២-ការបង្កើនបៀវត្សរ៍ និងការពង្រឹងការគ្រប់គ្រងនិយោជន៍ ៣-ការអភិវឌ្ឍសមត្ថភាព ៤-ការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមានកម្មវិធីកន្សោមអាទិភាពជាស្នូលនៃយុទ្ធសាស្ត្រ ។

ការកែលំអសេវាសាធារណៈត្រូវធ្វើឡើងទៅតាមសភាពការណ៍ជាក់ស្តែង និងជាជំហានៗ ដើម្បីប្រែក្លាយសេវាសាធារណៈឱ្យមាន **គុណភាពល្អ តម្លៃថោកខ្ញី សាមញ្ញ អាចជឿទុកចិត្តបាន ឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការ និងបង្កលក្ខណៈងាយស្រួល**[១] ដល់អ្នកប្រើប្រាស់សេវា។

ឯកសារគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ កំណត់អំពីនិយមន័យ ប្រភេទនៃសេវា

(១) អត្ថន័យពាក្យគន្លឹះ មានពន្យល់ក្នុងឧបសម្ព័ន្ធទី១

សាធារណៈរបស់រដ្ឋ គោលដៅ វិធីសាស្ត្រ យន្តការនៃការអនុវត្ត ការកែលំអបទដ្ឋានគតិយុត្ត ការសម្របសម្រួលអនុវត្ត ។

ទន្ទឹមនឹងនេះ ឯកសារគោលនយោបាយនេះ ក៏ជាឯកសារគោលសម្រាប់អនុវត្តចំពោះការងារកំណែទម្រង់នានា សំដៅដល់ការកែលំអការផ្តល់សេវាសាធារណៈ ដោយឈរលើបទពិសោធន៍ល្អៗដែលបានអនុវត្តកន្លងមក និងកំពុងអនុវត្តនាពេលបច្ចុប្បន្ន។

## I -និយមន័យ

**សេវាសាធារណៈ** ដូចមានចែងក្នុងគោលនយោបាយនេះ ត្រូវបានកំណត់ន័យដូចខាងក្រោម:

"រាល់សកម្មភាពទាំងឡាយ ដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ចក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈគឺជា **សេវាសាធារណៈ**"។

"ស្ថាប័នមានសមត្ថកិច្ច" នៅក្នុងន័យនេះ គឺសំដៅដល់ស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋ ឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋ ដែលបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន ។

"ស្ថាប័នទទួលសមត្ថកិច្ច" នៅក្នុងន័យនេះ គឺសំដៅដល់ផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបានសិទ្ធិ និងភារកិច្ចពីរដ្ឋ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ។

ការគ្រប់គ្រង ការត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋទៅលើផ្នែកឯកជន និងសង្គមស៊ីវិលដែលរដ្ឋបានប្រគល់សិទ្ធិអំណាចឱ្យ ត្រូវធ្វើឡើងផ្អែកលើលក្ខខណ្ឌដូចមានចែងក្នុងសេចក្តីសម្រេច កិច្ចព្រមព្រៀង ឬកិច្ចសន្យាដែលបានប្រគល់ភារកិច្ចក្នុងវង្វង់ដែនសមត្ថកិច្ចមួយច្បាស់លាស់ និងពិនិត្យទៅលើសកម្មភាពការងារលទ្ធផលដែលសម្រេចបាន គោលដៅទៅអនាគត និងផលប៉ះពាល់ផ្សេងៗជាយថាហេតុ ដែលអាចកើតមានចំពោះសង្គមជាតិ។

## II-ប្រភេទនៃសេវាសាធារណៈរបស់រដ្ឋ

សេវាសាធារណៈដូចបានកំណត់ន័យខាងលើ និងដែលមានចែងក្នុងគោលនយោបាយនេះ ត្រូវបានចងក្រង និងប្រមូលផ្តុំជា ៧ ប្រភេទធំៗទៅតាមវិស័យ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន ដូចខាងក្រោម :

### ១- ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ

ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ គឺជាសេវាទទួលខុសត្រូវផ្តាច់មុខរបស់រដ្ឋ ដែលផ្តល់ដោយអង្គភាពរដ្ឋ ឬនីតិបុគ្គលនៃនីតិសាធារណៈ ដែលរដ្ឋបានប្រគល់សិទ្ធិអំណាចឱ្យ ដើម្បីអនុវត្ត ។ ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋមានដូចជា: លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ បញ្ជីអត្រានុកូលដ្ឋាន សំបុត្របញ្ជាក់កំណើត ប័ណ្ណសំគាល់យានយន្ត អាកាសយាន និងនាវា វិញ្ញាប័ណ្ណប័ត្រទទួលស្គាល់កម្មសិទ្ធិ

អត្តសញ្ញាណប័ណ្ណប្រជាពលរដ្ឋខ្មែរ សៀវភៅគ្រួសារ ការធ្វើនីត្យានុកូលកម្ម ជាដើម។

ពាក់ព័ន្ធទៅនឹងចង្កោមនៃសេវាសាធារណៈនេះ ការរៀបចំ និង ការប្រតិបត្តិការនៃការផ្តល់សេវាត្រូវទទួលខុសត្រូវដោយរដ្ឋ ឬភ្នាក់ងាររបស់រដ្ឋ។

**២- ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម**

ចង្កោមសេវាពាក់ព័ន្ធផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការស្នាក់នៅ ការធ្វើដំណើរ ការប្រាស្រ័យទាក់ទងរបស់ប្រជាពលរដ្ឋ និងសុវត្ថិភាពសង្គម គឺជាសមត្ថកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ច នគរបាលជាតិ កងរាជអាវុធហត្ថ និងកងយោធពលខេមរភូមិន្ទគ្រប់លំដាប់ថ្នាក់ទូទាំងប្រទេស ។ ចង្កោមសេវានេះជាសេវាដ៏ចាំបាច់ និងមិនអាចខ្វះបាន ដើម្បីធានាបរិយាកាសល្អដល់ការអភិវឌ្ឍសង្គមជាតិ ការកាត់បន្ថយភាព

ក្រិក្រ ភាពសុខសាន្តរបស់ប្រជាពលរដ្ឋ និងជាទំនុកចិត្តដល់វិនិយោគិន ធុរជន ក្នុងការប្រកបរបរអាជីវកម្ម និងជំនួញជួញដូរ ។

ពាក់ព័ន្ធទៅនឹងចង្កោមនៃសេវាសាធារណៈនេះ ការរៀបចំ និង ការប្រតិបត្តិការនៃការផ្តល់សេវាត្រូវធ្វើឡើងដោយរដ្ឋ ឬ ភ្នាក់ងាររបស់រដ្ឋ។

## ៣- ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល

ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល ដូចជា វិវាទរវាងប្រជាពលរដ្ឋ និង ប្រជាពលរដ្ឋ ឬរវាងប្រជាពលរដ្ឋ និង អ្នករាជការ ឬ រវាងប្រជាពលរដ្ឋ និងផ្នែកឯកជន ឬរវាងអ្នករាជការ និង ផ្នែកឯកជនជាដើម សេវាដោះស្រាយវិវាទនេះធ្វើឡើងតាមរូបភាព ២ យ៉ាង :

-តាមរយៈក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជា

អ្នកសម្របសម្រួល និង ដោះស្រាយចំពោះករណីវិវាទ មិនធ្ងន់ធ្ងរ ដើម្បីសម្រួលដល់គូភាគីទាំងសងខាង ដោយមិនចាំបាច់ពឹងផ្អែកតែទៅលើតុលាការ និងកាត់បន្ថយការកកស្ទះសំណុំរឿងនៅតុលាការ ។

- ក្នុងករណីគូភាគីវិវាទ មិនទទួលយកនូវដំណោះស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ នោះការដោះស្រាយវិវាទ ត្រូវធ្វើឡើងតាមរយៈតុលាការ។

ភាពជឿទុកចិត្តរបស់អ្នកប្រើប្រាស់សេវា និង អ្នកពាក់ព័ន្ធទាំងអស់ អាស្រ័យទៅលើការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ នៅក្នុងបរិបទនៃនីតិរដ្ឋ ។ ដូចនេះ រាល់សកម្មភាពកែលំអប្រព័ន្ធការងារទាំងអស់ ត្រូវរៀបចំឡើងជាជំហាន១ និងដោយប្រុងប្រយ័ត្ន ក្នុងទិសដៅបង្កើនគុណភាព និង ប្រសិទ្ធភាពនៃសេវាកម្មយុត្តិធម៌។

**៤-ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកំពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូចនិងមធ្យម បរិស្ថានវិនិយោគ និងការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ**

**ក- ការលើកកំពស់កិច្ចការពាណិជ្ជកម្ម**

រាជរដ្ឋាភិបាល ដែលជាអ្នករៀបចំយុទ្ធសាស្ត្រ និងជាអ្នកគ្រប់គ្រងការអភិវឌ្ឍ ដើម្បីធ្វើឱ្យបរិស្ថានធុរកិច្ចកាន់តែប្រសើរសម្រាប់វិស័យឯកជន បានចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ។ អាទិភាពជាពិសេសនឹងត្រូវផ្តោតទៅលើការរៀបចំឱ្យកាន់តែប្រសើរឡើងនូវបរិស្ថានរួមសម្រាប់ការអភិវឌ្ឍវិស័យឯកជន តាមរយៈវិធានការជាក់ស្តែងនានា :

១-ពង្រឹងអភិបាលកិច្ចល្អ ទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន ។

២-កាត់បន្ថយរាល់បែបបទស្មុគស្មាញ និង វែង

អន្ទាយ នៅតាមក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ ដល់ការនាំចេញ នាំចូល ។

៣- បំបាត់ចោលនូវភារកិច្ចជាន់គ្នារបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញដំណើរការត្រួត ពិនិត្យតែមួយកន្លែងឱ្យមានប្រសិទ្ធភាព។

៤- ពង្រឹងការអនុវត្តយន្តការការិយាល័យ "ច្រក ចេញចូលតែមួយ"នៅតាមបណ្តាច្រកអន្តរជាតិ។

**ខ-សហគ្រាសធុនតូច និងមធ្យម :**

រាជរដ្ឋាភិបាល បន្តជំរុញការអភិវឌ្ឍសហគ្រាស ធុនតូច និងមធ្យមតាមរយៈគោលនយោបាយ :

១- លើកទឹកចិត្តដល់សហគ្រាស ធុនតូចនិង មធ្យម ជាពិសេសតាមរយៈការផ្តល់ឥណទាន រយៈពេលមធ្យម និង រយៈពេលវែង

២- ទប់ស្កាត់ការរត់គេចពន្ធគ្រប់ប្រភេទ

៣- កាត់បន្ថយបែបបទការចុះបញ្ជី និងការរៀប

ចំដំណើរការក្រុមហ៊ុន ។

៤- សម្រួលដល់ការនាំចេញនាំចូលតាមរយៈការកាត់បន្ថយបែបបទស្មុគស្មាញក្នុងការស្នើសុំអាជ្ញាប័ណ្ណ និងលិខិតអនុញ្ញាតផ្សេងៗ ។ល។

៥- កាត់បន្ថយពេលវេលា និង កាត់បន្ថយថ្លៃសេវាកម្មក្នុងការអនុញ្ញាតឱ្យដំណើរការផលិតកម្ម នៃសហគ្រាសធុនតូច និងមធ្យមតាមរយៈការអនុវត្តយន្តការការិយាល័យច្រកចេញចូលតែមួយ ។

៦- ផ្តល់ការគាំពារដល់សហគ្រាសមួយចំនួនក្នុងរយៈពេលមួយសមស្រប ។

៧- ជំរុញឱ្យមានសម្ព័ន្ធភាពរវាងសហគ្រាសធុនតូច និងមធ្យម ជាមួយនឹងឧស្សាហកម្មធុនធំ ជាដើម ។

ដើម្បីសម្រេចគោលដៅខាងលើ រាជរដ្ឋាភិបាល

យកចិត្តទុកដាក់ :

១- ជំរុញលើកទឹកចិត្តដល់ការផលិតទំនិញបម្រើទីផ្សារក្នុងស្រុកជំនួសការនាំចូល ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រនៃការបង្កើតមូលដ្ឋានផលិតកម្មទំនិញក្នុងប្រទេសឱ្យបានច្រើនស្របទៅនឹងយុគសម័យនៃតំបន់ភាវូបនីយកម្ម និងសកលភាវូបនីយកម្ម

២- រៀបចំយុទ្ធសាស្ត្របង្កើនសមត្ថភាពប្រកួតប្រជែងសម្រាប់សហគ្រាសធុនតូច និងមធ្យម

៣- រៀបចំផែនការសកម្មភាព និង បទប្បញ្ញត្តិនានា ដើម្បីគ្រប់គ្រង តាមដានត្រួតពិនិត្យនិងគាំទ្រដល់ដំណើរការរបស់សហគ្រាសធុនតូច និង មធ្យម ។

**គ- បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជន**

ក្នុងការកសាង និង ថែទាំហេដ្ឋារចនាសម្ព័ន្ធ

ពាក់ព័ន្ធនឹងការងារនេះ រាជរដ្ឋាភិបាលនឹងចាត់វិធានការចាំបាច់ ដើម្បីពង្រឹងនិងកែលំអបរិស្ថានវិនិយោគ និងធុរកិច្ច រួមមាន គោលនយោបាយលើកទឹកចិត្ត លិខិតបទដ្ឋានសម្រាប់ណែនាំ និងជំរុញការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ ។

រចនាសម្ព័ន្ធនៃផ្នែកពាក់ព័ន្ធទៅនឹងចង្កោមសេវានេះ ដែលមិនទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការជាចាំបាច់ក្នុងការសម្រួលដល់ការធ្វើអាជីវកម្ម ការវិនិយោគទុន និងការអភិវឌ្ឍផ្នែកឯកជន ត្រូវធ្វើការកែសម្រួលឱ្យបានសមស្រប និងឱ្យបានឆាប់រហ័សទៅតាមស្ថានភាពជាក់ស្តែង និង ធនធានដែលមាន ។

## ៥- <u>ចង្កោមសេវាសង្គមកិច្ច</u> <u>វប្បធម៌</u> <u>និងកិច្ចការនារី</u>

ចង្កោមសេវានេះ រួមមានសេវាអប់រំ (លើក

កំពស់គុណភាពសេវាអប់រំសម្រាប់ទាំងអស់គ្នា សំភារៈសិក្សាគ្រប់គ្រាន់ និងសិទ្ធិទទួលបានសេវាអប់រំជាមូលដ្ឋាន) សេវាអនាម័យនិងសុខភាព (បង្កលក្ខណៈងាយស្រួល គុណភាព ប្រសិទ្ធភាព ដើម្បីផ្គត់ផ្គង់សេវាសុខាភិបាលមូលដ្ឋានប្រកបដោយសមធម៌ និងនិរន្តរភាពជូនប្រជាពលរដ្ឋគ្រប់រូប ជាពិសេសជនក្រីក្រ និងក្រុមជនងាយរងគ្រោះ) សេវាសម្រាប់ការកំសាន្ត សេវាសង្គមកិច្ច សេវាគាំពារកុមារកំព្រា កុមារងាយរងគ្រោះ ជនពិការ សេវាលើកស្ទួយ និងការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសេវាដទៃទៀត ដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។

**៦- ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត**

ការផ្តល់សេវានៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គឺជាអាទិភាពចំបងមួយរបស់រាជរដ្ឋាភិបាល

ដើម្បីជំរុញ និងបង្កើនល្បឿនកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ត្រូវផ្តោតជាសំខាន់លើការបន្តការកសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនរួមមាន: ផ្លូវថ្នល់ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងអាកាសយានដ្ឋាន ដែលអាចតភ្ជាប់ទីក្រុងទៅជនបទ និងគ្រប់ទីកន្លែងទូទាំងប្រទេស កសាងមន្ទីរពេទ្យ សាលារៀន អណ្តូងទឹក ប្រព័ន្ធទឹកស្អាត ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី ថាមពល បច្ចេកវិទ្យាព័ត៌មាន ប្រៃសណីយ៍ និងទូរគមនាគមន៍។ល។ ពាក់ព័ន្ធនឹងចង្កោមសេវានេះ រាជរដ្ឋាភិបាលមានគោលនយោបាយលើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសផ្នែកឯកជន។

**៧- <u>ចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូល ការធ្វើវិចារណកម្មចំណាយ និងការបើកផ្តល់</u>**

ចង្កោមសេវានេះ ពាក់ព័ន្ធនឹងការកែលំអការគ្រប់គ្រងចំណូល ចំណាយ និងការបើកផ្តល់ ឱ្យមានតម្លាភាព និងប្រសិទ្ធភាពខ្ពស់ជាងមុន សំដៅកាត់បន្ថយការលំបាករបស់អ្នកប្រើប្រាស់សេវា ។

ដើម្បីសម្រួលដល់ការអនុវត្ត ក្រសួង ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធនឹងចង្កោមសេវាណាមួយក្នុងចំណោមចង្កោមសេវាទាំង ៧ ខាងលើ ត្រូវរៀបចំចងក្រងបញ្ជីសេវានេះឱ្យបានសមស្រប ។

ក្នុងករណីមានការវិវត្តនៃសេដ្ឋកិច្ចទីផ្សារ បច្ចេកវិទ្យាទំនើប និងតម្រូវការជាក់ស្តែងដទៃទៀត ដែលកើតមានឡើងពីការវិវត្តរបស់សង្គមជាតិ សេវាសាធារណៈនឹងត្រូវកំណត់តាមស្ថានការណ៍វិវត្តនោះ ។

ការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ ទោះបីជាតាមយន្តការ ទីកន្លែង និងកាលៈទេសៈណាក៏ដោយ ត្រូវគិតទៅដល់លទ្ធភាព និងការគាំទ្រដល់ជនក្រីក្រ

ជនពិការ ចាស់ជរា និងកុមារ ទាំងនៅក្នុងទីក្រុង និង
នៅជនបទ ក្នុងការទទួលយកសេវាទៅប្រើប្រាស់ ។

## III- គោលដៅ

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការផ្តល់សេវាសាធារណៈ គឺដើម្បី"**បំរើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង**" មានន័យថា រដ្ឋបាលសាធារណៈត្រូវ :

១-ធានាភាពងាយស្រួលក្នុងការទទួលយកសេវាទៅប្រើប្រាស់

ផ្តល់ព័ត៌មានគ្រប់គ្រាន់ ច្បាស់លាស់ និងងាយយល់ កាត់បន្ថយការិយាធិបតេយ្យ និងនីតិវិធីស្មុគស្មាញ សំដៅកាត់បន្ថយការលំបាករបស់អ្នកប្រើប្រាស់សេវាក្នុងការស្វែងរកសេវាដោយខ្លួនឯង និងចំណាយបន្ថែមទៅលើអ្នករត់ការក្រៅផ្លូវការ ។

២-ផ្តោតទៅលើតម្រូវការជាក់ស្តែងរបស់អ្នកប្រើប្រាស់សេវា

កន្លងមក មន្ត្រីរាជការ ក្នុងឥរិយាបថជា អ្នក

**គ្រប់គ្រង** បានកំណត់ជាស្រេចនូវប្រភេទសេវាដែលត្រូវផ្តល់ជូនអ្នកប្រើប្រាស់ ទោះជាសេវាមួយចំនួនអ្នកប្រើប្រាស់មិនត្រូវការក៏ដោយ។ ប៉ុន្តែក្នុងឥរិយាបថជា **អ្នកផ្តល់សេវា** គឺត្រូវកំណត់ប្រភេទសេវាទៅតាមតម្រូវការរបស់ទីផ្សារ និងរបស់អ្នកប្រើប្រាស់វិញ ។

៣-ផ្តល់សេវាឱ្យចំទីកន្លែងនៃតម្រូវការរបស់អ្នកប្រើប្រាស់សេវា

រដ្ឋបាលសាធារណៈ ត្រូវផ្តល់សេវា ដល់ទីកន្លែងដែលអ្នកប្រើប្រាស់ត្រូវការ លើកលែងតែក្នុងករណីពិសេសមួយចំនួន ដែលមិនអាចផ្តត់ផ្គង់បាន ឧទាហរណ៍ សេវាវះកាត់បេះដូងដែលបច្ចុប្បន្ននេះមានតែមួយកន្លែងគត់នៅរាជធានីភ្នំពេញ។

ក្នុងន័យនេះ រដ្ឋបាលសាធារណៈ ត្រូវតែបង្វិតឱ្យនៅជិតប្រជាពលរដ្ឋ ដើម្បីសម្រួលការទទួលយក

សេវាទៅប្រើប្រាស់ ។ ឧទាហរណ៍ បើអ្នកប្រើប្រាស់ត្រូវការប្រភេទសេវាណាមួយ នៅតំបន់ណាមួយ យើងត្រូវកំណត់ឱ្យមានសេវាប្រភេទនោះ នៅតំបន់នោះតែម្តង មិនត្រូវឱ្យអ្នកប្រើប្រាស់រត់រកសេវានោះនៅភ្នំពេញទេ ។

៤- ត្រូវមានតម្លាភាព និងការទទួលខុសត្រូវក្នុងការផ្តល់សេវា

អ្នកផ្តល់សេវា ត្រូវផ្តល់ព័ត៌មានឱ្យបានទូលំទូលាយ ជាចំហដោយគ្មានការរើសអើង និងយកចិត្តទុកដាក់ផ្តល់សេវាឱ្យបានទាន់ពេលវេលាកំណត់ និងមានគុណភាព ជូនអ្នកប្រើប្រាស់ ដោយស្មារតីទទួលខុសត្រូវខ្ពស់។ ទន្ទឹមនឹងនោះ អ្នកផ្តល់សេវាក៏ត្រូវទុកលទ្ធភាពឱ្យអ្នកប្រើប្រាស់ តាមដាន និងស្វែងយល់អំពីនីតិវិធីនៃការផ្តល់សេវា និងអាចធ្វើការទិទៀន តវ៉ា ឬ ទាមទារឱ្យមានការកែលំអការខ្វះខាតផ្សេងៗតាមតម្រូវការ

សំដៅលើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពស្របតាមគោលការណ៍អភិបាលកិច្ចល្អ ។

៥- គុណភាព និងប្រសិទ្ធភាពនៃសេវា

អ្នកផ្តល់សេវា ត្រូវតែគោរពឱ្យបាននូវស្តង់ដារកំណត់ មានន័យថាអ្វីដែលបានកំណត់ជូនអ្នកប្រើប្រាស់ ត្រូវតែធ្វើឱ្យបានទៅតាមការកំណត់នោះ ទាំងតម្លៃ ទាំងពេលវេលា និង គុណភាព ។ គុណភាពនៃសេវា ត្រូវបានកំណត់ផ្អែកទៅលើការពេញចិត្តរបស់អ្នកប្រើប្រាស់សេវា នៅពេលដែលសេវាត្រូវបានផ្តល់ជូននោះ ឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍ទូទៅរបស់អ្នកប្រើប្រាស់ ។

សេវាទាំងឡាយណា ដែលរដ្ឋបាលសាធារណៈ ពុំទាន់មានលទ្ធភាពផ្តល់ជូនអ្នកប្រើប្រាស់បាន រដ្ឋអាចស្វែងរកដៃគូអភិវឌ្ឍន៍ដែលមានលទ្ធភាព ដើម្បីជួយសម្រួលដល់អ្នកប្រើប្រាស់សេវា ស្របតាមតម្រូវការ ។

## IV-វិធីសាស្ត្រ

ដើម្បីសម្រេចបាននូវគោលដៅខាងលើ ត្រូវមានវិធីសាស្ត្រសំខាន់ៗ ២ សម្រាប់អនុវត្ត :

១- ផ្លាស់ប្តូរអាកប្បកិរិយា និងទម្លាប់ការងាររបស់មន្ត្រីរាជការ ពី " **អ្នកគ្រប់គ្រង** " ទៅជា " **អ្នកផ្តល់សេវា** "។ នេះជាចំណុចគន្លឹះដ៏សំខាន់មួយព្រោះថា បើ-ទោះ បីជារបៀបរបប និង នីតិវិ-ធីនៃការអនុវត្តល្អយ៉ាងណា ក៏ដោយ តែ-បើមន្ត្រីរាជការមិនធ្វើការផ្លាស់ប្តូរឥរិយា បថរបស់ខ្លួនឱ្យទៅជាអ្នកបម្រើសេវាជូនអ្នកប្រើប្រាស់ដោយអស់ពីចិត្តពីថ្លើមទេនោះ ក៏មិនអាចផ្តល់សេវាប្រកបដោយគុណភាពនិងប្រសិទ្ធភាពជូនអ្នកប្រើប្រាស់បានដែរ។ អ្នកផ្តល់សេវាត្រូវបម្រើអ្នកប្រើប្រាស់សេវាឱ្យបានល្អទាំងពាក្យសំដី អាកប្បកិរិយា និង ការទំនាក់ទំនងការងារទូទៅ ហើយត្រូវផ្តល់សេវាទៅតាមពេលវេលា

និងទីកន្លែងដែលមានតម្រូវការ ។ ដើម្បីផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងគុណភាពជូនអ្នកប្រើប្រាស់ ទាមទារជាបឋមឱ្យមន្ត្រីរាជការទូទៅយល់ដឹងឱ្យបានច្បាស់លាស់អំពីទស្សនទាន **"អ្នកផ្តល់សេវា"** និង **"អ្នកប្រើប្រាស់សេវា"** ដើម្បីផ្លាស់ប្តូរផ្នត់គំនិតខាងលើ សំដៅកាត់បន្ថយការិយាធិបតេយ្យ ព្រមទាំងនីតិវិធីស្មុគស្មាញក្នុងការផ្តល់សេវា ។

ការផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថរបស់មន្ត្រីរាជការ ដែលបានចាក់ឫសដ៏ជ្រៅក្នុងទស្សនៈជា **"អ្នកគ្រប់គ្រង"** គឺជាការកែទម្រង់មួយដ៏លំបាក និងទាមទារពេលវេលាសមស្របសម្រាប់អនុវត្ត ។

២- កែប្រែរបៀបរបបការងារពី " **រចនាសម្ព័ន្ធមុខងារ** " ទៅជា " **រចនាសម្ព័ន្ធប្រតិបត្តិការ** "

វិធីសាស្ត្រនេះ គឺសំដៅកែលំអរបៀបរបបការងារនៅក្នុងរដ្ឋបាលសាធារណៈ ឱ្យកាន់តែបានល្អប្រសើរ

ឡើងឆ្ពោះទៅរកលទ្ធផល ជាកត្តាសំខាន់។ របៀបរបប ការងារតាមបែបរចនាសម្ព័ន្ធមុខងារ គឺធ្វើទៅតាមនីតិវិធី និងបទប្បញ្ញត្តិនានាដែលបានកំណត់ ដោយមិនគិតពីលទ្ធផល ប្រសិទ្ធភាព និងការពេញចិត្តរបស់អ្នកប្រើប្រាស់សេវាឡើយ ។

រចនាសម្ព័ន្ធប្រតិបត្តិការ ត្រូវអនុវត្តទៅតាមទស្សនទាន ២ គឺ ផ្នែកជួរមុខ និង ផ្នែកទ្រទ្រង់ ។

## ១- ផ្នែកជួរមុខ

ផ្នែកជួរមុខគឺជាផ្នែកដែលត្រូវធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយអ្នកប្រើប្រាស់សេវា។ ដើម្បីឱ្យផ្នែកជួរមុខ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវាជូនអ្នកប្រើប្រាស់សេវា មន្ត្រីរាជការ ឬភ្នាក់ងារដែលបម្រើការងារនៅក្នុងផ្នែកនេះ ត្រូវតែយល់ដឹងជារួម និងតាមវិស័យជំនាញនូវសេវាសាធារណៈនោះ និងត្រូវមានអាកប្បកិរិយាល្អ យកចិត្តទុកដាក់ចំពោះសេចក្តីត្រូវការ

និងជួយបំភ្លឺចម្ងល់ផ្សេងៗរបស់អ្នកប្រើប្រាស់សេវា ។

ផ្នែកជួរមុខមានភារកិច្ចផ្តល់ព័ត៌មាន ពន្យល់អំពីនីតិវិធីនៃការទទួលសេវា បញ្ជូន និងបែងចែកសំណុំឯកសារទៅតាមវិស័យជំនាញ ទទួលប្រាក់កម្រៃសេវា ព្រមទាំងផ្តល់លទ្ធផល និងសេចក្តីសម្រេចពាក់ព័ន្ធនឹងការស្នើសុំសេវា ទៅអ្នកប្រើប្រាស់សេវាវិញ ។

ក្នុងករណីចាំបាច់ ត្រូវផ្តល់ការណែនាំបន្ថែម និងជួយសម្រួលដល់ការបំពេញបែបបទ និងការទទួលពាក្យស្នើសុំពីអ្នកប្រើប្រាស់សេវាទាំងឡាយណាដែលពុំមានការយល់ដឹងច្បាស់លាស់ ដូចជាករណីអ្នកមិនចេះអក្សរជាដើម ។

## ២-ផ្នែកទ្រទ្រង់

ផ្នែកទ្រទ្រង់ គឺជាផ្នែកដ៏សំខាន់សម្រាប់ធានាឱ្យផ្នែកជួរមុខទទួលជោគជ័យ ។ ផ្នែកទ្រទ្រង់មានភារកិច្ចពិនិត្យពាក្យស្នើសុំ និងឯកសារនានា លើកយោបល់

និងបញ្ជូនតាមលំដាប់លំដោយទៅសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីសម្រេច និងប្រគល់លទ្ធផលទៅផ្នែកជួរមុខវិញ។

ការរៀបចំផ្នែកទ្រទ្រង់ ត្រូវផ្តោតលើកត្តាសំខាន់ៗ ៥ រួមមាន:

**១-<u>ធនធានមនុស្ស</u>** : មន្ត្រីរាជការត្រូវមានការយល់ដឹងអំពីទស្សនទាននៃការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព និងប្រសិទ្ធភាព ដោយត្រូវផ្លាស់ប្តូរឥរិយាបថ ទម្លាប់ និង របៀបរបបការងារពី " អ្នកគ្រប់គ្រង" ទៅជា "អ្នកផ្តល់សេវា " និងត្រូវបានទទួលការបណ្តុះបណ្តាលបង្កើនសមត្ថភាពដើម្បីពង្រឹងវិជ្ជាជីវៈ លើកកម្ពស់ចំណេះដឹង ចំណេះធ្វើ ព្រមទាំងស្មារតីទទួលខុសត្រូវ សំដៅផ្តល់សេវាជូនអ្នកប្រើប្រាស់ស្របតាមតម្រូវការ។

ក្នុងបរិបទនៃការគ្រប់គ្រងធនធានមនុស្ស ត្រូវយកចិត្តទុកដាក់ជាអាទិភាពចំពោះមន្ត្រីរាជការដែល

មានស្នាដៃការងារល្អ តាមរយៈការតម្លើងថ្នាក់ ឋានន្តរសក្តិ ការផ្តល់គ្រឿងឥស្សរិយយស និងការលើកទឹកចិត្តតាមរូបភាពផ្សេងៗទៀត។

**២-<u>ធនធានហិរញ្ញវត្ថុ</u>** ៖ ធនធានហិរញ្ញវត្ថុ ត្រូវតែស្របទៅនឹងផែនការសកម្មភាព និងផែនការការងារប្រចាំឆ្នាំរបស់វិស័យនីមួយៗ ។ ម្យ៉ាងទៀត ប្រតិបត្តិការសាច់ប្រាក់ ត្រូវតែធ្វើឡើងឱ្យទាន់ពេលវេលា តាមកាលបរិច្ឆេទដែលបានគ្រោងទុក។

**៣-<u>ការធ្វើផែនការ</u>** ៖ ផ្នែកទ្រទ្រង់ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិសម្រាប់ដំណើរការផ្តល់សេវាជូនអ្នកប្រើប្រាស់ឱ្យបានទាន់ពេលវេលាប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ផែនការដែលត្រូវរៀបចំរួមមាន៖ ផែនការការងារ ផែនការសកម្មភាព ផែនការថវិកា ផែនការហិរញ្ញវត្ថុ លទ្ធផលរំពឹងទុក និងហានិភ័យនានាជាដើម ។

### ៤-ការធ្វើអធិការកិច្ច ត្រួតពិនិត្យនិងការវាយតម្លៃ:

ការអនុវត្តផែនការសកម្មភាពនៃការផ្តល់សេវាសាធារណៈ ត្រូវមានការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធ្វើអធិការកិច្ច ដើម្បីឆ្លុះបញ្ចាំងអំពីសកម្មភាពដែលកំពុងដំណើរការ ធៀបទៅនឹងលទ្ធផលរំពឹងទុក ដែលបានកំណត់នៅក្នុងផែនការសកម្មភាព។

### ៥-បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍

ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ដែលជាមធ្យោបាយទំនើបអាចនាំឱ្យមានការប្រែប្រួលជាសារវ័ន្តនូវរបៀបរបបនៃការប្រាស្រ័យទាក់ទងរវាងរដ្ឋបាលសាធារណៈ និងអ្នកប្រើប្រាស់សេវា។ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នាំឱ្យកាត់បន្ថយបាននូវការិយាធិបតេយ្យ ពេលវេលា បង្កើនប្រសិទ្ធភាពការងារគ្រប់គ្រង និង លើកកំពស់គោលការណ៍តម្លាភាព ជាពិសេសជួយសម្រួលដល់

អ្នកប្រើប្រាស់សេវាឱ្យចូលយកព័ត៌មាន និង សេវាសា-ធារណៈបានគ្រប់ពេលវេលា និង គ្រប់ទីកន្លែង ។

ជារួម ការងាររបស់ផ្នែកជួរមុខ និងផ្នែកទ្រទ្រង់ត្រូវតែឆ្លើយតបគ្នាទៅវិញទៅមកដោយរលូន និងស៊ីសង្វាក់គ្នានៅគ្រប់ដំណាក់កាល ដើម្បីសម្រេចគោលដៅចុងក្រោយគឺ "បំរើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង" ។

## V-យន្តការនៃការអនុវត្ត

ការកំណត់យន្តការខាងក្រោមនេះ មានគោលបំណងជួយសម្រួលការងារដល់ក្រសួងស្ថាប័នទាំងអស់ក្នុងដំណើរការកែលំអ និងការបង្កើតស្តង់ដារក្នុងការប្រើប្រាស់យន្តការទាំងនេះ។ ក៏ប៉ុន្តែការអនុវត្តអាស្រ័យទៅលើកាលៈទេសៈ និងទិដ្ឋភាពជាក់ស្តែងនៃរដ្ឋបាលសាធារណៈរបស់កម្ពុជា។

ភាពជោគជ័យនៃការផ្តល់សេវាសាធារណៈអាស្រ័យទៅលើកិច្ចដំណើរការរបស់យន្តការទាំងអស់ ពេលវេលានៃការប្រព្រឹត្តទៅ និងតម្លៃនៃសេវា ។

យន្តការនៃការផ្តល់សេវាសាធារណៈ ត្រូវបានដំណើរការតាមជម្រើសដូចខាងក្រោម ៖

**១-ការកែលំអកិច្ចដំណើរការការងារ នៃការផ្តល់សេវាសាធារណៈ**

ការកែលំអកិច្ចដំណើរការការងារនៃការផ្តល់សេវាសាធារណៈ គឺជាយន្តការជាមូលដ្ឋានដើម្បីកែលំអការផ្តល់សេវាសាធារណៈដែលកំពុងដំណើរការនៅតាមក្រសួងស្ថាប័ន និងភ្នាក់ងាររបស់រដ្ឋទាំងអស់ តាមរយៈការលុបចោលនូវភាពជាន់គ្នា ឬភាពមិនច្បាស់លាស់នៃភារកិច្ច និងនីតិវិធីដែលមិនចាំបាច់។ ការងារនេះត្រូវផ្តោតទៅលើនីតិវិធី អភិក្រម ពេលវេលា តម្លៃនៃការចំណាយ ប្រសិទ្ធភាព ជំនឿទុកចិត្ត និងគុណភាពនៃសេវាសាធារណៈដែលអ្នកប្រើប្រាស់បានទទួល។

**២-ច្រកចេញចូលតែមួយ**

ច្រកចេញចូលតែមួយ ជាយន្តការនៃការផ្តល់

សេវាសាធារណៈដែលបង្កភាពងាយស្រួលដល់អ្នកប្រើប្រាស់ តាមនីតិវិធីសាមញ្ញ មានតម្លាភាព ប្រសិទ្ធភាព និងយកចិត្តទុកដាក់ចំពោះការផ្តល់យោបល់ និងការចាប់អារម្មណ៍របស់អ្នកប្រើប្រាស់សេវា។ យន្តការនេះប្រមូលផ្តុំជាចង្កោមនូវសេវាសាធារណៈមួយចំនួន ឱ្យមកនៅកន្លែងតែមួយ ទាំងកន្លែងស្នើសុំ និងកន្លែងទទួល ដោយកំណត់ពេលវេលាប្រគល់សេវា និងកំណត់តម្លៃច្បាស់លាស់។ បទពិសោធន៍ល្អៗដែលបានអនុវត្តកន្លងមកត្រូវយកមកធ្វើជាគំរូនៃការអនុវត្តនៅទូទាំងប្រទេស។

ការផ្តល់សេវាសាធារណៈតាមយន្តការការិយាល័យច្រកចេញចូលតែមួយ ត្រូវរៀបចំឡើងដោយកំណត់តួនាទី ភារកិច្ច និង ដែនសមត្ថកិច្ចឱ្យបានច្បាស់លាស់ ។

ការរៀបចំ និងការប្រព្រឹត្តទៅ ក្របខ័ណ្ឌ គោល

ការណ៍ នីតិវិធី និងរចនាសម្ព័ន្ធនៃការផ្តល់សេវាតាមយន្តការការិយាល័យច្រកចេញចូលតែមួយត្រូវធ្វើឡើងតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

## ៣-វិសហមជ្ឈការសេវាសាធារណៈ

ការរៀបចំអំណាចគ្រប់គ្រងរដ្ឋបាល គឺជាការងារអាទិភាព និងជាយុទ្ធសាស្ត្រ ដូចមានចែងក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៥។

" **វិសហមជ្ឈការ** " នៅក្នុងគោលនយោបាយនេះ កំណត់តែអំពីសេវាសាធារណៈ និងការផ្តល់សេវាសាធារណៈក្នុងក៏រិតនៃអំណាចគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិតាមប្រព័ន្ធរដ្ឋបាលឯកភាពប៉ុណ្ណោះ។

រដ្ឋបាលឯកភាពនៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ

នឹងជួយជំរុញកិច្ចសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធាណៈនៅក្នុងដែនដីរបស់ខ្លួន សំដៅជំរុញកិច្ចអភិវឌ្ឍន៍ និង ការផ្តល់សេវាសាធាណៈ ដើម្បីឆ្លើយតបតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

**៤-ទិដ្ឋភាពសេវាសាធារណៈ**

ផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ រដ្ឋបាលឃុំ សង្កាត់ មានតួនាទី ២ ប្រភេទគឺ:

១-តួនាទីបម្រើកិច្ចការមូលដ្ឋាន សម្រាប់បម្រើផលប្រយោជន៍ ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំសង្កាត់របស់ខ្លួន ។

២-តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ។

ក្នុងតួនាទីទាំង ២ ខាងលើនេះ រដ្ឋបាលឃុំ សង្កាត់ មានភារកិច្ចដូចមានចែងក្នុងមាត្រា៤៣ និង មាត្រា៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

ការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលឃុំ សង្កាត់ ត្រូវអនុវត្តជាជំហាន១ ផ្អែកលើស្ថានភាពជាក់ស្តែងនៃការវិវត្តរីកចម្រើនរបស់ទីផ្សារ និងទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់ ។

## ៥- គ្រឹះស្ថានសាធារណៈរដ្ឋបាល

គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជាយន្តការនៃការផ្តល់សេវាសាធារណៈមួយផ្សេងទៀត ដែលមានស្វ័យភាពខាងហិរញ្ញវត្ថុ ឬ រដ្ឋបាល និងជានីតិបុគ្គលនៃនីតិសាធារណៈ ដែលទទួលបន្ទុកជាចម្បងនូវបេសកកម្មផ្នែកសេវាសាធារណៈជាលក្ខណៈរដ្ឋបាល សង្គម សុខាភិបាល វប្បធម៌ វិទ្យាសាស្ត្រ ឬបច្ចេកទេស។

ក្នុងក្របខ័ណ្ឌនេះ គ្រឹះស្ថានសាធារណៈរដ្ឋបាល

ត្រូវមានលក្ខណ:សម្បត្តិជារួមដូចតទៅ :

១- នាមករណ៍ និង ទីស្នាក់ការ

២- មានកម្មវត្ថុដែលកំណត់អំពីប្រភេទសកម្មភាព

៣- មានក្រុមប្រឹក្សាភិបាលដើម្បីដឹកនាំគ្រប់គ្រង ដំណើរការ និងការគ្រប់គ្រងដោយឡែក

៤- មានថវិកាផ្ទាល់ខ្លួន

៥- មានទ្រព្យសម្បត្តិសម្រាប់ធ្វើសកម្មភាព ដូច មានគ្រោងទុកក្នុងកម្មវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

៦- មានសមត្ថភាពចុះកិច្ចសន្យា និងប្តឹង ឬការពារខ្លួននៅចំពោះមុខច្បាប់និងតុលាការ និង

៧- ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណីលើទង្វើរបស់អ្នកតំណាងស្របច្បាប់ ឬនិយោជិតរបស់ខ្លួន ក្នុងពេលបំពេញការងារជូនគ្រឹះស្ថាន។

គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបង្កើតឡើង ដោយអនុក្រឹត្យ តាមសំណើរួមរបស់ក្រសួង ឬអាជ្ញាធរ អាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវកំណត់ ជាពិសេសនូវបេសកកម្ម បុព្វសិទ្ធិ កាតព្វកិច្ច សមាស ភាពនៃក្រុមប្រឹក្សាភិបាល ព្រមទាំងវិធានពិសេស សម្រាប់អនុវត្តក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យលើ គ្រឹះស្ថាន និងត្រូវបញ្ជាក់ផងដែរនូវក្រសួង ឬអាជ្ញាធរ អាណាព្យាបាល ។

លក្ខខណ្ឌ និងគោលការណ៍ទាំងឡាយនៃការ បង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវអនុលោមតាម ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថាន សាធារណៈរដ្ឋបាល។

**៦-សហគ្រាសសាធារណៈ**

សហគ្រាសសាធារណៈ គឺជាយន្តការផ្តល់សេវាសាធារណៈរបស់រដ្ឋដែលស្ថិតក្រោមការគ្រប់គ្រងនៃនីតិឯកជន និង នីតិសាធារណៈ និងជានីតិបុគ្គលដែលមានស្វ័យភាពហិរញ្ញវត្ថុ ហើយដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ។ សហគ្រាសសាធារណៈមានបេសកកម្ម បង្កលក្ខណៈដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម មានជាអាទិ៍ ការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព។

សហគ្រាសសាធារណៈ មានទម្រង់ជា៖

-គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច

-ក្រុមហ៊ុនរដ្ឋ

-ក្រុមហ៊ុនចម្រុះ ដែលក្នុងនោះរដ្ឋកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលលើសពី ៥១ ភាគរយនៃដើមទុនក្រុមហ៊ុន ឬ សិទ្ធិបោះឆ្នោត។

សហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោមអា

ណាព្យាបាលបច្ចេកទេសនៃក្រសួង ឬអាជ្ញាធរសាធារណៈណាមួយ អាស្រ័យលើប្រភេទនៃសកម្មភាពរបស់សហគ្រាសនោះ។

**ក. <u>គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច</u>**

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច គឺជានីតិបុគ្គលនៃនីតិសាធារណៈដែលមានស្វ័យភាពហិរញ្ញវត្ថុ ។ គ្រឹះស្ថាននេះផលិតទំនិញ និងសេវាសម្រាប់បម្រើទីផ្សារ។

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចត្រូវបង្កើតឡើងដោយអនុក្រឹត្យ តាមការស្នើរួមគ្នារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាល ។ អនុក្រឹត្យនេះកំណត់ជាអាទិ៍អំពីភារកិច្ច ដើមទុន ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល សមាសភាពក្រុមប្រឹក្សាភិបាល ការរៀបចំរដ្ឋបាល និងហិរញ្ញវត្ថុ វិធាននៃ

ការប្រព្រឹត្តទៅរបស់គ្រឹះស្ថាន។

**ខ. ក្រុមហ៊ុនរដ្ឋ**

ក្រុមហ៊ុនរដ្ឋ គឺជាក្រុមហ៊ុនដែលមានដើមទុនទាំងអស់ជារបស់រដ្ឋ។ ក្រុមហ៊ុនរដ្ឋ គឺជាយន្តការនៃការផ្តល់សេវាសាធារណៈជូនអ្នកប្រើប្រាស់សេវា ដោយធ្វើការប្រកួតប្រជែងនៅក្នុងបរិស្ថានសេដ្ឋកិច្ចទីផ្សារ ហើយដែលរដ្ឋអាចដំណើរការទៅបានដោយខ្លួនឯង។

ក្រុមហ៊ុនរដ្ឋ ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យ តាមការស្នើរួមគ្នាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល។ អនុក្រឹត្យនេះត្រូវកំណត់ជាអាទិ៍អំពីកម្មវត្ថុរបស់ក្រុមហ៊ុន ទម្រង់គតិយុត្ត ក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាបាល របបត្រួតពិនិត្យដែលត្រូវអនុវត្ត សមាសភាពរបស់ក្រុមប្រឹក្សាភិបាល។

ក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណា

ព្យាបាលបច្ចេកទេស ទទួលខុសត្រូវបំពេញទម្រង់បែបបទនៃការបង្កើតក្រុមហ៊ុនដោយ :

- រៀបចំលក្ខន្តិកៈរបស់ក្រុមហ៊ុន ដោយមានការព្រមព្រៀងជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចាត់ចែងចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- បំពេញទម្រង់បែបបទទាំងអស់តាមគោលការណ៍និងបែបបទទាំងឡាយ នៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម។

គ. <u>ក្រុមហ៊ុនចម្រុះ</u>

ក្រុមហ៊ុនចម្រុះ គឺជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងតាមគោលការណ៍ និងតាមបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ហើយដែលដើមទុនត្រូវបានកាន់កាប់រួមគ្នាដោយនីតិបុគ្គល ឬរូបវន្តបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ។ កាលណាភាគកម្មលាភសាធារណៈលើសពី ៥១ភាគរយ នៃដើមទុន ឬសិទ្ធិបោះឆ្នោត ក្រុមហ៊ុនចម្រុះត្រូវបានចាត់ទុកជា

សហគ្រាសសាធារណៈ។

តំណាងរបស់រដ្ឋ ឬតំណាងរបស់គ្រឹះស្ថានសាធារណៈនៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចំរុះ ត្រូវបានចាត់តាំងដោយការសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ តំណាងរបស់ក្រុមហ៊ុនរដ្ឋនៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុននោះ ក្រោយពីមានមតិយោបល់ឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីរបស់តំណាងក្នុងការបំពេញភារកិច្ចរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនចម្រុះ ត្រូវធ្លាក់លើរដ្ឋ លើគ្រឹះស្ថានសាធារណៈ ឬលើក្រុមហ៊ុនរដ្ឋ តែអ្នកតំណាងត្រូវទទួលខុសត្រូវដោយខ្លួនឯង ខាងផ្នែកព្រហ្មទណ្ឌ។

លក្ខខណ្ឌ និងគោលការណ៍ទាំងឡាយនៃការ

បង្កើតសហគ្រាសសាធារណៈដែលមានទម្រង់ជាគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនចម្រុះ ដែលក្នុងនោះរដ្ឋកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលលើសពី ៥១ ភាគរយនៃដើមទុនក្រុមហ៊ុន ឬសិទ្ធិបោះឆ្នោត ត្រូវអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ និងអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃ ទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ។

## ៧-កិច្ចសន្យា

កិច្ចសន្យា គឺជាយន្តការមួយនៃការផ្តល់សេវាសាធារណៈ ក្នុងពេលដែលរដ្ឋពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការដាក់ឱ្យដំណើរការនូវការផ្តល់សេវា ស្រប

តាមតម្រូវការរបស់អ្នកប្រើប្រាស់សេវា សំដៅពង្រឹងប្រសិទ្ធភាពការងារ លើកកំពស់គុណភាពសេវា ដើម្បីទទួលបាននូវទំនុកចិត្តពីអ្នកប្រើប្រាស់សេវា ។

ការអនុវត្តយន្តការកិច្ចសន្យា ត្រូវមានលក្ខខណ្ឌការងារច្បាស់លាស់ ដោយផ្អែកលើលទ្ធផលរំពឹងទុក លក្ខខណ្ឌនៃការអនុវត្ត ធនធានចាំបាច់សម្រាប់ដំណើរការ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ។ ភាគីជាប់កិច្ចសន្យា ត្រូវប្រើប្រាស់មន្ត្រីរាជការនៅនឹងកន្លែង ដែលអាចទទួលប្រាក់ឧបត្ថម្ភផ្អែកលើសមត្ថភាពមុខងារទទួលខុសត្រូវ និងលទ្ធផលដែលសម្រេចបាន។ ក្នុងករណីចាំបាច់ ភាគីជាប់កិច្ចសន្យា អាចជ្រើសរើសបុគ្គលិកបន្ថែមក្រៅពីមន្ត្រីរាជការរបស់រដ្ឋដើម្បីបំពេញការងារទៅតាមតម្រូវការ ។

ការសម្រេចដាក់ឱ្យដំណើរការផ្តល់សេវាសាធារណៈតាមយន្តការកិច្ចសន្យា ត្រូវធ្វើឡើងតាមគំនិត

ផ្តួចផ្តើមរបស់ក្រសួង ស្ថាប័នសាមី ដោយមានការយល់ព្រមពីរាជរដ្ឋាភិបាល ។

**៨-ភ្នាក់ងារប្រតិបត្តិការពិសេស**

ការគ្រប់គ្រង និងការផ្តល់សេវាសាធារណៈតាមយន្តការភ្នាក់ងារប្រតិបត្តិការពិសេស គឺជាទស្សនទានមួយថ្មី ដែលរបៀបនៃការដំណើរការត្រូវធ្វើឡើងតាមគោលដៅកំណត់ ។

ភ្នាក់ងារប្រតិបត្តិការពិសេស គឺជាអង្គភាពមួយរបស់ក្រសួង ស្ថាប័ន ដែលចាត់តាំងឡើងដើម្បីអនុវត្តឱ្យបានសម្រេចនូវគោលដៅពិសេសណាមួយរបស់រាជរដ្ឋាភិបាល ដោយផ្អែកលើលក្ខខណ្ឌបេសកកម្ម ហើយដែលមានភាពអនុគ្រោះ និងភាពបត់បែនបានទៅលើការរៀបចំ និងការប្រព្រឹត្តទៅ ការគ្រប់គ្រងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ខុសពីអង្គភាពដទៃទៀតនៅក្នុងក្រសួង ស្ថាប័ននោះ ។

ការរៀបចំឱ្យមានភ្នាក់ងារប្រតិបត្តិការពិសេសនេះ មានគោលដៅលើកកំពស់ប្រសិទ្ធភាពការងារ ពង្រឹងគណនេយ្យភាព ជំរុញនិវានុវត្តន៍ និងគំនិតផ្តួចផ្តើម សំដៅពង្រឹងវប្បធម៌នៃការយកចិត្តទុកដាក់ដល់អ្នកប្រើប្រាស់សេវា ។

លក្ខខណ្ឌបេសកកម្មដើម្បីអនុវត្តយន្តការភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវផ្អែកលើចំណុចជាមូលដ្ឋាន ៤ យ៉ាងគឺ :

១- ផ្តោតការយកចិត្តទុកដាក់លើតម្រូវការជាអាទិភាពរបស់អ្នកប្រើប្រាស់សេវា ដោយកំណត់ឱ្យបានច្បាស់លាស់អំពីប្រភេទ គុណភាព និងតម្លៃនៃសេវាដែលត្រូវផ្តល់ជូន ។

២- កំណត់ឱ្យបានច្បាស់លាស់អំពីលទ្ធផលរំពឹងទុក និងធនធានចាំបាច់នានា ។

៣- កំណត់ឱ្យបានច្បាស់លាស់អំពីការរៀបចំ

និងការប្រព្រឹត្តទៅរបស់ភ្នាក់ងារនេះ ។

៤- កំណត់ឱ្យបានច្បាស់លាស់អំពីយន្តការនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ។

## ៩-ឯកជនភាវូបនីយកម្ម

ក្នុងករណីចាំបាច់ខ្លះ ឯកជនភាវូបនីយកម្ម អាចត្រូវបានជ្រើសរើសជាយន្តការមួយដើម្បីសម្រួលដល់ការផ្តល់សេវាសាធារណៈជូនអ្នកប្រើប្រាស់សេវា។

ការដឹកនាំកម្មវិធីឯកជនភាវូបនីយកម្ម ត្រូវអនុលោមទៅតាមបទប្បញ្ញត្តិកំណត់ និងផ្សព្វផ្សាយឱ្យសាធារណជនបានយល់ដឹងអំពីដំណើរការនៃការប្រព្រឹត្តទៅ។ ការធ្វើឯកជនភាវូបនីយកម្មត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមការស្នើសុំពីក្រសួង ស្ថាប័នសាមី ។

## VI-ការកែលំអបទដ្ឋានគតិយុត្ត

ក្នុងគោលដៅកែលំអការផ្តល់សេវាសាធារណៈ ឱ្យដំណើរការបានដោយជោគជ័យនិងប្រកបដោយប្រសិទ្ធភាព ការកែសម្រួលបទដ្ឋានគតិយុត្ត ដែលមានស្រាប់ ឬការបង្កើតបទដ្ឋានគតិយុត្តថ្មី ឱ្យស្របទៅតាមតម្រូវការជាក់ស្តែង គឺជាការចាំបាច់ ។

ដូចនេះ ការងារដែលត្រូវអនុវត្ត ត្រូវផ្តោតការយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចខាងក្រោម ៈ

១- កែសម្រួលបទដ្ឋានគតិយុត្តណាដែលជាន់មុខងារគ្នា ដើម្បីឱ្យមានភាពរលូន ។

២- កែសម្រួលបទដ្ឋានគតិយុត្តណាដែលកំណត់នីតិវិធីស្មុគស្មាញ ឱ្យមានភាពសាមញ្ញ ។

៣- កែសម្រួលបទដ្ឋានគតិយុត្តដែលមានស្រាប់ឱ្យស្របតាមតម្រូវការជាក់ស្តែង។

៤- រៀបចំ និងតាក់តែងបទដ្ឋានគតិយុត្តថ្មី ទៅតាមប្រភេទនិងវិស័យនៃសេវាសាធារណៈ។

ក្នុងការកែសម្រួលបទដ្ឋានគតិយុត្ត ដែលមានស្រាប់ ឬការបង្កើតបទដ្ឋានគតិយុត្តថ្មី ក្រសួង ស្ថាប័នសាមីត្រូវរួមសហការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីឱ្យបទដ្ឋានគតិយុត្តទាំងនោះមានភាពរលូន ស្របទៅនឹងគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈនេះ ។

## VII - ការសម្របសម្រួលអនុវត្ត

ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ត្រូវបានរាជរដ្ឋាភិបាលប្រគល់ភារកិច្ច និងតួនាទីផ្តួចផ្តើមគំនិតសម្របសម្រួល ជំរុញ និងឃ្លាំមើលការអនុវត្ត ទាំងផ្នែកបច្ចេកទេសនិងបទពិសោធន៍ ដើម្បីឱ្យគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈនេះ អនុវត្តទៅបានប្រកបដោយជោគជ័យ។

ក្រសួង ស្ថាប័ន និងអាជ្ញាធរខេត្ត ក្រុង ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីឱ្យការអនុវត្តមានប្រសិទ្ធភាព ផ្លែផ្កា និងប្រកបដោយជោគជ័យ ។ ជាងនេះទៅទៀត គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរខេត្ត ក្រុង ត្រូវទទួលខុសត្រូវចំពោះគុណភាព និងការផ្តល់សេវាសាធារណៈដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល គ្រប់ក្រសួង

ស្ថាប័ន ត្រូវសហការគ្នាធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងបណ្តុះបណ្តាលដល់មន្ត្រីរាជការក្រោមឱវាទរបស់ខ្លួន ឱ្យបានយល់ដឹងជ្រួតជ្រាបអំពីគោលនយោបាយនេះ ព្រមទាំងដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅសាលាភូមិន្ទរដ្ឋបាល ។

ការអនុវត្តគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈនេះ ទាមទារឱ្យមានការចូលរួមយ៉ាងសកម្មពីគ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ សង្គមស៊ីវិល ព្រមទាំងភាគីពាក់ព័ន្ធទាំងអស់ក៏ដូចជាដៃគូអ្នកផ្តល់ជំនួយនានារបស់កម្ពុជា សំដៅបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរឡើង ៕

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ ២០០៦

## ឧបសម្ព័ន្ធទី១

## អត្ថន័យពាក្យគន្លឹះ

១- **គុណភាពល្អ** : សំដៅទៅលើការពេញចិត្តរបស់អ្នកប្រើប្រាស់សេវា នៅពេលដែលសេវាត្រូវបាន ផ្ដល់ជូនទៅតាមលក្ខខណ្ឌកំណត់ (នីតិវិធី ពេលវេលា និងតម្លៃ) និងឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍ទូទៅរបស់អ្នកប្រើប្រាស់។

២- **តម្លៃថោក** : តម្លៃសេវាដែលត្រូវបង់ ត្រូវមានកម្រិតមួយសមរម្យ ស្របតាមទីកន្លែង និងលទ្ធភាពរបស់អ្នកប្រើប្រាស់។

៣- **ខ្លី** : សំដៅទៅលើនីតិវិធីនៃការផ្ដល់សេវាតាមរចនាសម្ព័ន្ធប្រតិបត្តិ គឺលុបបំបាត់ការិយាធិប


ឧបសម្ព័ន្ធទី១

អត្ថន័យពាក្យគន្លឹះ

១- គុណភាពល្អ : សំដៅទៅលើការពេញចិត្តរបស់អ្នកប្រើប្រាស់សេវា នៅពេលដែលសេវាត្រូវបាន ផ្ដល់ជូនទៅតាមលក្ខខណ្ឌកំណត់ (នីតិវិធី ពេលវេលា និងតម្លៃ) និងឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍ទូទៅរបស់អ្នកប្រើប្រាស់។

២- តម្លៃថោក : តម្លៃសេវាដែលត្រូវបង់ ត្រូវមានកម្រិតមួយសមរម្យ ស្របតាមទីកន្លែង និងលទ្ធភាពរបស់អ្នកប្រើប្រាស់។

៣- ខ្លី : សំដៅទៅលើនីតិវិធីនៃការផ្ដល់សេវាតាមរចនាសម្ព័ន្ធប្រតិបត្តិ គឺលុបបំបាត់ការិយាធិប

ឧបសម្ព័ន្ធទី១

អត្ថន័យពាក្យគន្លឹះ

១- គុណភាពល្អ : សំដៅទៅលើការពេញចិត្តរបស់អ្នកប្រើប្រាស់សេវា នៅពេលដែលសេវាត្រូវបាន ផ្ដល់ជូនទៅតាមលក្ខខណ្ឌកំណត់ (នីតិវិធី ពេលវេលា និងតម្លៃ) និងឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍ទូទៅរបស់អ្នកប្រើប្រាស់។

២- តម្លៃថោក : តម្លៃសេវាដែលត្រូវបង់ ត្រូវមានកម្រិតមួយសមរម្យ ស្របតាមទីកន្លែង និងលទ្ធភាពរបស់អ្នកប្រើប្រាស់។

៣- ខ្លី : សំដៅទៅលើនីតិវិធីនៃការផ្ដល់សេវាតាមរចនាសម្ព័ន្ធប្រតិបត្តិ គឺលុបបំបាត់ការិយាធិប

ឧបសម្ព័ន្ធទី១

អត្ថន័យពាក្យគន្លឹះ

១- គុណភាពល្អ : សំដៅទៅលើការពេញចិត្តរបស់អ្នកប្រើប្រាស់សេវា នៅពេលដែលសេវាត្រូវបាន ផ្ដល់ជូនទៅតាមលក្ខខណ្ឌកំណត់ (នីតិវិធី ពេលវេលា និងតម្លៃ) និងឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍ទូទៅរបស់អ្នកប្រើប្រាស់។

២- តម្លៃថោក : តម្លៃសេវាដែលត្រូវបង់ ត្រូវមានកម្រិតមួយសមរម្យ ស្របតាមទីកន្លែង និងលទ្ធភាពរបស់អ្នកប្រើប្រាស់។

៣- ខ្លី : សំដៅទៅលើនីតិវិធីនៃការផ្ដល់សេវាតាមរចនាសម្ព័ន្ធប្រតិបត្តិ គឺលុបបំបាត់ការិយាធិប

តេយ្យមិនចាំបាច់ ។

៤- **សាមញ្ញ :** មានន័យថា លក្ខខណ្ឌផ្សេងៗ ដែលអ្នកប្រើប្រាស់សេវាត្រូវបំពេញ ដើម្បីទទួលបានសេវាយកទៅប្រើប្រាស់ មានលក្ខណៈងាយយល់ទាំងទម្រង់បែបបទ និងនីតិវិធី ។

៥- **អាចជឿទុកចិត្តបាន :** ការផ្តល់សេវា ត្រូវអនុវត្តទៅតាមនីតិវិធី និងបទដ្ឋាននានាដែលបានកំណត់ទុកជាមុន និងមានការដឹងឮជាទូទៅ។ ប្រសិនបើអ្នកផ្តល់សេវាអនុវត្តផ្ទុយពីអ្វីដែលបានកំណត់ នោះនឹងធ្វើឱ្យអ្នកប្រើប្រាស់សេវាបាត់បង់នូវជំនឿទុកចិត្ត ។

៦- **ឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការៈ** ប្រភេទនៃសេវា នីតិវិធី និងពេលវេលានៃការ

តេយ្យមិនចាំបាច់ ។

៤- **សាមញ្ញ :** មានន័យថា លក្ខខណ្ឌផ្សេងៗ ដែលអ្នកប្រើប្រាស់សេវាត្រូវបំពេញ ដើម្បីទទួលបានសេវាយកទៅប្រើប្រាស់ មានលក្ខណៈងាយយល់ទាំងទម្រង់បែបបទ និងនីតិវិធី ។

៥- **អាចជឿទុកចិត្តបាន :** ការផ្តល់សេវា ត្រូវអនុវត្តទៅតាមនីតិវិធី និងបទដ្ឋាននានាដែលបានកំណត់ទុកជាមុន និងមានការដឹងឮជាទូទៅ។ ប្រសិនបើអ្នកផ្តល់សេវាអនុវត្តផ្ទុយពីអ្វីដែលបានកំណត់ នោះនឹងធ្វើឱ្យអ្នកប្រើប្រាស់សេវាបាត់បង់នូវជំនឿទុកចិត្ត ។

៦- **ឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការៈ** ប្រភេទនៃសេវា នីតិវិធី និងពេលវេលានៃការ

តេយ្យមិនចាំបាច់ ។

៤- **សាមញ្ញ :** មានន័យថា លក្ខខណ្ឌផ្សេងៗ ដែលអ្នកប្រើប្រាស់សេវាត្រូវបំពេញ ដើម្បីទទួលបានសេវាយកទៅប្រើប្រាស់ មានលក្ខណៈងាយយល់ទាំងទម្រង់បែបបទ និងនីតិវិធី ។

៥- **អាចជឿទុកចិត្តបាន :** ការផ្តល់សេវា ត្រូវអនុវត្តទៅតាមនីតិវិធី និងបទដ្ឋាននានាដែលបានកំណត់ទុកជាមុន និងមានការដឹងឮជាទូទៅ។ ប្រសិនបើអ្នកផ្តល់សេវាអនុវត្តផ្ទុយពីអ្វីដែលបានកំណត់ នោះនឹងធ្វើឱ្យអ្នកប្រើប្រាស់សេវាបាត់បង់នូវជំនឿទុកចិត្ត ។

៦- **ឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការៈ** ប្រភេទនៃសេវា នីតិវិធី និងពេលវេលានៃការ

តេយ្យមិនចាំបាច់ ។

៤- **សាមញ្ញ :** មានន័យថា លក្ខខណ្ឌផ្សេងៗ ដែលអ្នកប្រើប្រាស់សេវាត្រូវបំពេញ ដើម្បីទទួលបានសេវាយកទៅប្រើប្រាស់ មានលក្ខណៈងាយយល់ទាំងទម្រង់បែបបទ និងនីតិវិធី ។

៥- **អាចជឿទុកចិត្តបាន :** ការផ្តល់សេវា ត្រូវអនុវត្តទៅតាមនីតិវិធី និងបទដ្ឋាននានាដែលបានកំណត់ទុកជាមុន និងមានការដឹងឮជាទូទៅ។ ប្រសិនបើអ្នកផ្តល់សេវាអនុវត្តផ្ទុយពីអ្វីដែលបានកំណត់ នោះនឹងធ្វើឱ្យអ្នកប្រើប្រាស់សេវាបាត់បង់នូវជំនឿទុកចិត្ត ។

៦- **ឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការៈ** ប្រភេទនៃសេវា នីតិវិធី និងពេលវេលានៃការ

ផ្ដល់សេវា ត្រូវបានកំណត់ដោយឈរលើមូលដ្ឋាន នៃតម្រូវការរបស់អ្នកប្រើប្រាស់ជាអាទិភាព។

៧- **បង្កលក្ខណៈងាយស្រួល :** អ្នកផ្ដល់សេវាសម្រួលដល់អ្នកប្រើប្រាស់សេវាទាំងការងារទំនាក់ទំនង ការបំពេញបែបបទ និងការទទួលយកសេវាត្រឡប់ទៅវិញ ៕

ផ្ដល់សេវា ត្រូវបានកំណត់ដោយឈរលើមូលដ្ឋាន នៃតម្រូវការរបស់អ្នកប្រើប្រាស់ជាអាទិភាព។

៧- **បង្កលក្ខណៈងាយស្រួល :** អ្នកផ្ដល់សេវាសម្រួលដល់អ្នកប្រើប្រាស់សេវាទាំងការងារទំនាក់ទំនង ការបំពេញបែបបទ និងការទទួលយកសេវាត្រឡប់ទៅវិញ ៕

ផ្ដល់សេវា ត្រូវបានកំណត់ដោយឈរលើមូលដ្ឋាន នៃតម្រូវការរបស់អ្នកប្រើប្រាស់ជាអាទិភាព។

៧- **បង្កលក្ខណៈងាយស្រួល :** អ្នកផ្ដល់សេវាសម្រួលដល់អ្នកប្រើប្រាស់សេវាទាំងការងារទំនាក់ទំនង ការបំពេញបែបបទ និងការទទួលយកសេវាត្រឡប់ទៅវិញ ៕

ផ្ដល់សេវា ត្រូវបានកំណត់ដោយឈរលើមូលដ្ឋាន នៃតម្រូវការរបស់អ្នកប្រើប្រាស់ជាអាទិភាព។

៧- **បង្កលក្ខណៈងាយស្រួល :** អ្នកផ្ដល់សេវាសម្រួលដល់អ្នកប្រើប្រាស់សេវាទាំងការងារទំនាក់ទំនង ការបំពេញបែបបទ និងការទទួលយកសេវាត្រឡប់ទៅវិញ ៕

## ឧបសម្ព័ន្ធទី២៖ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល



**ឧបសម្ព័ន្ធទី៣៖ ផែនការសកម្មភាពអភិបាលកិច្ចទី ២**

## ផែនការសកម្មភាពនៅក្នុងបរិបទនៃ ស្ថិរភាព សន្តិភាព សន្តិសុខ និងប្រជាធិបតេយ្យ

| |
|---|
| កំណែទម្រង់រដ្ឋបាល និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ |
| កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ |
| វិមជ្ឈការ វិសហមជ្ឈការ និង ការងារនគរបាល |
| កំណែទម្រង់សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| ការអភិវឌ្ឍសង្គមកិច្ច (កាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង អប់រំ សុខាភិបាល ការងារអភិវឌ្ឍន៍ជនបទ) |
| សមធម៌យេនឌ័រ |

| កំណែទម្រង់កងយោធពលខេមរភូមិន្ទ | គោលនយោបាយដីធ្លី | កំណែទម្រង់ការគ្រប់គ្រងធនធានធម្មជាតិ | | | |
|---|---|---|---|---|---|
| | | ព្រៃឈើ | ជលផល | ធនធានទឹក | បរិស្ថាន |